
www.kidsofdestiny.org
Kids of Destiny®

## 1.03 កំណើតរបស់ព្រះបុត្រា (យេស៊ូវ)

**លូកា ២: ១-២០**

មានក្មេងស្រីម្នាក់ឈ្មោះម៉ារា ព្រះទ្រង់បានទតឃើញនាងប្រព្រឹត្តរឿងល្អៗជាច្រើន។ ទ្រង់ឃើញពីដួងចិត្តដ៏អស្ចារ្យរបស់នាង ហើយទ្រង់ដឹងថានាងស្រឡាញ់និងគោរពតាមព្រះបន្ទូលរបស់ព្រះអង្គខ្លាំងណាស់។ ព្រះទ្រង់បានជ្រើសរើសនាងសម្រាប់ការអស្ចារ្យដ៏ពិសេសមួយរបស់ទ្រង់ ហើយបានបញ្ជូនទេវតាកាព្រីយ៉ែលឲ្យទៅប្រាប់នាង។ ថ្ងៃមួយនៅពេលម៉ារារវល់ធ្វើការងាររបស់នាង នាងសំលឹងមើលទៅលើ ហើយឃើញពន្លឺចែងចាំង។ ពេលនោះ ទេវតាកាព្រីយ៉ែល ដែលបាននិយាយប្រាប់នាងថា កុំអោយខ្លាចឡើយ "ព្រះទ្រង់សព្វព្រះហឫទ័យជាមួយនាងហើយ" គាត់បន្តទៀតថា "ម៉ារាអើយ នាងនឹងមានកូនប្រុសម្នាក់ដែលជាបុត្ររបស់ព្រះដ៏ជាព្រះ ហើយនាងនឹងត្រូវហៅទ្រង់ថា យេស៊ូវ ដែលមានន័យថា ព្រះអង្គសង្គ្រោះ ។ ទ្រង់នេះហើយដែលព្រះទ្រង់បានសន្យាថានឹងជួយសង្គ្រោះរាស្ត្រទ្រង់ឲ្យរួចពីអំពើបាបរបស់ពួកគេ"។

ម៉ារាមានការតក់ស្លុតជាខ្លាំង និងមិនយល់ពីអ្វីគ្រប់យ៉ាងដែលកំពុងកើតឡើងឡើយ។ ប៉ុន្តែ ដោយមានចិត្តដឹងគុណ នាងបានតបថា "ខ្ញុំជាអ្នកបំរើរបស់ព្រះអម្ចាស់ សូមឲ្យសំរេចតាមអ្វីដែលព្រះសព្វព្រះហឫទ័យចុះ" ហើយប្រាកដណាស់៩ខែក្រោយមកទារកតូចរបស់នាង ក៏បានរួចរាល់សម្រាប់ប្រសូត ។

ពេលនោះម៉ារា និងយ៉ូសែបត្រូវធ្វើដំណើរទៅភូមិបេថ្លេហិមដែលជាដំណើរដ៏វែងឆ្ងាយនិងពិបាក។ ពេលនោះនាងម៉ារាកំពុងមានផ្ទៃពោះត្រូវជិះលើសត្វលា ដែលមើលទៅវាមិនស្រួលប៉ុន្មានទេ។ ពួកគេនឿយហត់ជាខ្លាំងណាស់ នៅពេលដែលពួកគេបានដើររកតាមផ្ទះសំណាក់នីមួយៗ ក្នុងភូមិបេថ្លេហិម ប៉ុន្តែគ្មាននរណាមានបន្ទប់សល់ទេ។ ទោះជាយ៉ាងណាក៏ដោយមានម្ចាស់ផ្ទះសំណាក់ម្នាក់បានប្រាប់ពួកគេថា ពួកគេអាចស្នាក់នៅក្នុងក្រោលសត្វរបស់គាត់បាន វាជាកន្លែងដែលសត្វរបស់គាត់រស់នៅ។ នៅកន្លែងនោះ ប្រឡាក់ មានក្លិនមិនល្អ ហើយមានសត្វនៅពាសពេញ ដែលកំពុងតែឆ្ងល់ពីអ្វីដែលកំពុងកើតឡើង ព្រះយេស៊ូវបានប្រសូតមកនៅក្នុងក្រោលសត្វ ទីនោះគ្មានគ្រែ ឬអង្រឹងយោលទេ គឺមានតែជម្រើសតែមួយប៉ុណ្ណោះ គឺស្នូកសត្វ! ស្នូកសត្វ ជាកន្លែងដាក់ចំណីសម្រាប់សត្វស៊ី។ ម៉ារាដាក់ចំបើងទន់ៗខ្លះនៅក្នុងស្នូក ហើយរុំទារកតូចយេស៊ូវនៅក្នុងសំពត់ ហើយផ្តេកនៅក្នុងស្នូកសត្វនៅទីនោះតែម្តង។

នៅប៉ែកម្ខាងទៀតនៃទីក្រុង នៅលើទីទួលភ្នំមានពួកគង្វាលកំពុងតែមើលថែហ្វូងចៀមរបស់ពួកគេ។ ភ្លាមៗនោះពន្លឺដ៏ភ្លឺខ្លាំង និងក្រុមទេវតាជាច្រើនកំពុងច្រៀងពេញផ្ទៃមេឃ។ ពួកគេចាប់ផ្តើមច្រៀងរៀបរាប់ពីរបៀបដែលព្រះយេស៊ូវជាស្តេចបានប្រសូតមក។ បន្ទាប់មកទេវតាមួយរូបបានប្រាប់ទៅកាន់ពួកគង្វាល ដោយប្រាប់ពួកគេឱ្យទៅរកទារកតូចនោះ ដែលកំពុងផ្ទំនៅក្នុងស្នូកសត្វ! ដូច្នេះពួកគង្វាលរត់យ៉ាងលឿនតាមដែលអាចធ្វើទៅបាន ហើយពួកគេក៏បានឃើញទារកបរិសុទ្ធ ពួកគេបានឱនក្បាលចុះហើយថ្វាយបង្គំទ្រង់។ បន្ទាប់មកពួកគេបានរត់ទៅតាមផ្លូវ ប្រាប់មនុស្សគ្រប់គ្នានូវដំណឹងល្អនេះ!

ក្នុងពេលជាមួយគ្នានោះ នៅប្រទេសមួយផ្សេងទៀត មានអ្នកប្រាជ្ញបីនាក់បានឃើញផ្កាយចម្លែកនៅលើមេឃ ។ វាជាផ្កាយថ្មីមួយ ហើយពួកគេបានដឹងថាមានស្តេចមួយអង្គបានប្រសូត្រមក។ ពួកគេបានរៀបគម្រោងធ្វើដំណើរដ៏វែងឆ្ងាយ ឆ្លងកាត់វាលខ្សាច់ និងភ្នំដើម្បីស្វែងរកស្តេចដែលទើបនឹងប្រសូតនោះ។ ពួកគេបានរៀបចំអំណោយថ្វាយទ្រង់ ហើយអំណោយដ៏ថ្លៃៗ ដើម្បីផ្តល់កិត្តិយសដល់ព្រះយេស៊ូវ។ អំណោយទាំងនោះមាន មាស កំញាន និងគ្រឿងក្រអូប។ នៅពេលដែលពួកគេទៅដល់ទីក្រុងយេរូសាឡិម ពួកគេបានគាល់សួរស្តេចហេរ៉ូឌថា តើទ្រង់អាចផ្តល់ការណែនាំផ្លូវសម្រាប់ពួកគេបានទេ ប៉ុន្តែវាបានធ្វើឲ្យស្តេចហេរ៉ូឌក្រោធជាខ្លាំង។ ស្តេចហេរ៉ូឌមិនចង់មានស្តេចផ្សេងទៀតនោះទេ។ ទ្រង់ចង់សម្លាប់ស្តេចថ្មីនោះ ដូច្នេះទ្រង់ប្រាប់អ្នកប្រាជ្ញឲ្យមករាយការណ៍ប្រាប់ទ្រង់វិញពេលក្រោយ។ ប៉ុន្តែព្រះបានបញ្ជូនទេវតាមកក្នុងសុបិន ប្រាប់អ្នកប្រាជ្ញឲ្យធ្វើដំណើរតាមផ្លូវផ្សេងទៅស្រុករបស់ពួកគេវិញ ។

**យ៉ូហាន ៣:១៦** ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម៉្លេះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ ។

1.03 **កំណើតរបស់ព្រះមហាក្សត្រ**

**លូកា ២: ១-២០ កំណត់សម្គាល់**

១) មានក្មេងស្រីម្នាក់ឈ្មោះម៉ារា។ នាងស្រឡាញ់ព្រះ ហើយគោរពតាមបទបញ្ញត្តិរបស់ទ្រង់។ ព្រះបានជ្រើសរើសនាងសម្រាប់ការអស្ចារ្យដ៏ពិសេសមួយ។

២) ទេវតាមួយបានមករកនាងម៉ារា ហើយប្រាប់នាងថា នាងនឹងមានកូន។ ទារកនេះនឹងក្លាយជាព្រះរាជបុត្រារបស់ព្រះ។ ទេវតាបាននិយាយថា "អ្នកនឹងព្រះនាមទ្រង់ថាយេស៊ូវ" ដែលមានន័យថាព្រះអង្គសង្គ្រោះ។

៣) ម៉ារាមិនយល់អ្វីគ្រប់យ៉ាងដែលកំពុងកើតឡើងទេ ប៉ុន្តែនាងបាននិយាយថា "ខ្ញុំជាអ្នកបម្រើរបស់ព្រះ។ ខ្ញុំនឹងធ្វើអ្វីដែលទ្រង់ចង់អោយខ្ញុំតាម»។

៤) ម៉ារា និង យ៉ូសែប ត្រូវទៅបេថ្លេហិម។ ពួកគេត្រូវការកន្លែងស្នាក់នៅ ប៉ុន្តែផ្ទះសំណាក់ទាំងអស់ពេញ។ ដោយសារតែហេតុនេះ ពួកគេបានស្នាក់នៅក្នុងក្រោលសត្វជាកន្លែងសត្វទាំងនោះរស់នៅ។ ព្រះយេស៊ូវបានប្រសូត្រនៅទីនោះ។ ទ្រង់ត្រូវបានគេដាក់នៅក្នុងស្នូកសត្វមួយ ដែលជាកន្លែងដាក់ចំណីសម្រាប់សត្វស៊ី។

៥) មានអ្នកគង្វាលចៀមខ្លះនៅលើភ្នំក្បែរនោះ កំពុងមើលហ្វូងចៀមរបស់ពួកគេ។ ទេវតាបានប្រាប់គេថា ចូរទៅរកបុត្រតូចនោះ។ ពួកគេបានក្រាបថ្វាយបង្គំព្រះយេស៊ូវ។

៦) នៅស្រុកឆ្ងាយ មានអ្នកប្រាជ្ញបានឃើញផ្កាយថ្មីនៅលើមេឃ ហើយដឹងថា មានស្តេចមួយអង្គបានប្រសូត្រ។ ស្តេចហេរ៉ូដចង់ឱ្យពួកគេរាយការណ៍មកទ្រង់វិញ នៅពេលពួកគេបានរកឃើញព្រះយេស៊ូវ។ ប៉ុន្តែ ទេវតាមួយបានប្រាប់ទៅកាន់ពួកអ្នកប្រាជ្ញក្នុងសុបិនថា ដោយហាមពួកគេមិនអោយទៅឯស្តេចហេរ៉ូឌ ព្រោះទ្រង់ចង់សម្លាប់បុត្រតូចយេស៊ូវ។ ក្រោយពីបានឃើញបុត្រតូចហើយ ពួកគេត្រឡប់ទៅផ្ទះវិញតាមផ្លូវផ្សេង។

**សំណួរ៖**

១) តើព្រះបានជ្រើសរើសអ្នកណាសម្រាប់ការអស្ចារ្យដ៏ពិសេសរបស់ទ្រង់?

២) តើទេវតាបានប្រាប់ម៉ារាអំពីអ្វី?

៣) តើម៉ារា និងយ៉ូសែបបានទៅទីក្រុងណា?

៤) តើព្រះយេស៊ូវបានប្រសូត្រនៅកន្លែងណា?

៥) តើទេវតាបាននិយាយទៅកាន់អ្នកណានៅលើភ្នំក្បែរនោះ?

៦) ហេតុអ្វីបានជាស្តេចហេរ៉ូឌសួរអ្នកប្រាជ្ញឲ្យប្រាប់ទ្រង់ថាបុត្រតូចយេស៊ូវនៅឯណា?

**ចម្លើយ៖**

១) ក្មេងស្រីម្នាក់ឈ្មោះ ម៉ារា ដែលស្រឡាញ់ និងស្តាប់បង្គាប់ព្រះ ត្រូវបានជ្រើសរើសសម្រាប់ការអស្ចារ្យដ៏ពិសេសរបស់ទ្រង់។

2) ទេវតាបានប្រាប់ម៉ារាថានាងនឹងមានកូន។ បុត្រនោះនឹងក្លាយជាព្រះរាជបុត្រារបស់ព្រះ ហើយនាងគួរតែដាក់ឈ្មោះទ្រង់ថា យេស៊ូវ។

៣) ម៉ារា និង យ៉ូសែប ត្រូវទៅក្រុងបេថ្លេហិម។

៤) ព្រះយេស៊ូវបានប្រសូតក្នុងក្រោលសត្វមួយ ដែលជាកន្លែងសត្វទាំងនោះរស់នៅ។

5) ទេវតាបាននិយាយទៅកាន់អ្នកគង្វាលដោយប្រាប់ពួកគេឱ្យទៅរកទារក។

៦) ស្តេចហេរ៉ូឌចង់សម្លាប់ព្រះយេស៊ូវ។

**យ៉ូហាន ៣:១៦** ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ ។



www.kidsofdestiny.org